I- ធីស្តីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៦៤ អនក្រ
ស្តីពីការបង្កើត ៣ កងពលតូចធំពាវព្រៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋានកងទ័ពជាតិកម្ពុជា ។
- ផ្អែកតាមសំណូមពរចាំបាច់ នៃការកសាងកងយោធពលខេមរភូមិន្ទ ចំពោះមុខ ។
- ផ្អែកតាមសំណើរបស់ឯកឧត្តមសហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

សំរេច

មាត្រា ១ : ត្រូវបានបង្កើត ៣ កងពលតូចទ័ពព្រៃ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់អគ្គសេនាធិការ ដោយយកសញ្ញាសំគាល់ កងពលតូចលេខ ១ ២ ៣ ទ័ពព្រៃ ។

មាត្រា ២ : រចនាសម្ព័ន្ធចាត់តាំង ភារកិច្ច និង សិទ្ធិរបស់កងពលតូចទ័ពព្រៃ អាស្រ័យដោយ អគ្គសេនាធិការកំណត់ ។

មាត្រា ៣ : ប្រគល់ជូនអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាជាក់ស្តែងក្នុងការរៀបចំកងពលតូចទ័ពព្រៃនីមួយៗ ខាងលើ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះដែលចូលជាធរមានចាប់តាំងពីថ្ងៃ ឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ : ៦៥ អនក្រ
ស្តីពីការរៀបចំឃុំ ស្រុក ក្នុងខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជាពិសេសមាត្រា ១២៦
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបង្កើតឃុំថ្មីចំនួនបី ក្នុងស្រុកថ្មពួកគឺ :

១_ឃុំគោកកឋិន មានចំនួនប្រាំបួនភូមិ ដែលកាត់យកប្រាំពីរភូមិ របស់ឃុំថ្មពួក គឺ ÷ ភូមិដី ភូមិស្មៅ ភូមិទ្រាស ភូមិគោកកឋិន ភូមិតាសៀវ ភូមិជន្លះដៃ ភូមិតាត្រៃ និងកាត់យកពីរភូមិរបស់ឃុំភូមិថ្មី គឺភូមិព្រះឈរ និងភូមិគោកខ្ពស់ ។

២_ឃុំគំរូមានបួនភូមិ ដែលកាត់យកបីភូមិរបស់ឃុំថ្មពួក គឺ ភូមិតាយឹង ភូមិអញ្ចាញខ្ទង់ ភូមិគំរូ និងកាត់យកភូមិកណ្តាល របស់ឃុំគោករមៀត ។

៣- ឃុំរលួសមានប្រាំមួយភូមិដែលកាត់យកពីឃុំស្វាយចេកគឺ ៖ ភូមិស្ទឹង ភូមិខ្វាវកើត ភូមិស្លែង ភូមិបែកចានថ្មីភូមិតាអុងកើត ភូមិរលួស ។

មាត្រា ២ ៖ ត្រូវបានបំបែកភូមិសាស្ត្រស្រុកថ្មពួក ជាពីរស្រុកគឺ ៖ ស្រុកស្វាយចេក និងស្រុកថ្មពួក ។

-ស្រុកស្វាយចេកមានឃុំចំណុះចំនួនប្រាំបី គឺ ឃុំស្វាយចេក ឃុំរលួស ឃុំតាបែន ឃុំស្លក្រាម ឃុំសារង្គ ឃុំតាផូ ឃុំផ្គាំ ឃុំទ្រាស ។ ទីតាំងរដ្ឋបាលរបស់សាលាស្រុកស្វាយចេក តាំងនៅភូមិស្ទឹង ឃុំស្វាយចេក ។

-ស្រុកថ្មពួកមានឃុំចំណុះចំនួនប្រាំមួយគឺ ៖ ឃុំថ្មពួក ឃុំគោកកបិន ឃុំគំរូ ឃុំបន្ទាយឆ្មារ ឃុំភូមិថ្មី ឃុំគោករមៀត ។ ទីតាំងរដ្ឋបាលរបស់ស្រុកថ្មពួកតាំងនៅ ភូមិវត្តចាស់ ឃុំថ្មពួក ។

មាត្រា ៣ ៖ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តបន្ទាយមានជ័យ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ។

មាត្រា ៥ ៖ អនុក្រឹត្យនេះមាន អានុភាពគតិយុត្តិចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៦៦ អនក្រ
ស្តីពីការកែសំរួលសមាសភាពគណៈកម្មការ
ជាតិអចិន្ត្រៃយ៍ដើម្បី សំរបសំរួលកិច្ចការឯកជន
ភាវូបនីយកម្ម និង ការជំរុញទិសំយជំណាំកៅស៊ូ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងអនុក្រឹត្យលេខ ៥២ អនក្រ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍ដើម្បីសំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម និង ធំរុញវិស័យជំណាំកៅស៊ូ

សំរេច

មាត្រាតែមួយ : សមាសភាពគណៈកម្មការជាតិអចិន្ត្រៃយ៍ ដើម្បីសំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម និង ការជំរុញវិស័យជំណាំកៅស៊ូ ដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យលេខ ៥២ អនក្រ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤ ត្រូវបានកែសំរួលដូចតទៅ :

-លោក ហ្វ្រីលិពម៉ូណាំង ទីប្រឹក្សាបច្ចេកទេសអមអគ្គនាយកដ្ឋានកៅស៊ូ ជាសមាជិកសង្កេតការណ៍ ទទួលបន្ទុកជួយឯកឧត្តម **តាច សេខហួរ** និងឯកឧត្តម តេង ឡាវ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

***

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១២០ អនក្រ
ស្តីពីការជូន មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤·